ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ២០២......សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១០

# ប្រកាស

## ស្តីពី

## ការផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនវិស្វកម្មឯករាជ្យ សម្រាប់គ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់សារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើវិសោធនកម្មច្បាប់នៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែម និងការកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ អនុក្រឹត្យលេខ ១៣៤ អនក្រ/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារនិង អគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១២៦ អនក្រ/បក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ អគារសហកម្មសិទ្ធិ
- បានឃើញ អនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញ ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧
- បានឃើញ ប្រកាសលេខ ២១៦ សហវ.ប្រក.ឧហ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- បានឃើញ ប្រកាសលេខ ១៤៩៧ សហវ.ប្រក ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- បានឃើញ ប្រកាសលេខ ១២២២ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- បានឃើញ ប្រកាសលេខ ០៧៥ ប្រក/ដ.ន.ស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់
- បានឃើញ ប្រកាសលេខ ០៣៥ ប្រក.ដនស/អសណ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលប្រការ ៦ នៃប្រកាសលេខ ១៩២ ប្រក.ដនស/អសណ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់
- បានឃើញ ប្រកាសលេខ ១៩២ ប្រក.ដនស/អសណ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់
- យោងការចាំបាច់ក្នុងការគ្រប់គ្រងការអភិវឌ្ឍអចលនវត្ថុ ។

# សម្រេច

**ប្រការ ១: - គោលបំណង**

ក្នុងគោលបំណងឈានទៅរកគ្រប់គ្រងការអភិវឌ្ឍអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងប្រកាសលេខ ១២២២ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រេចចេញប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនវិស្វកម្មឯករាជ្យសម្រាប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុដែលមានខ្លឹមសារដូចតទៅ ÷

**ប្រការ២: - ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ**

វិស្វករសំណង់អគារដែលបញ្ចប់ការសិក្សា និងបានឆ្លងកាត់បទពិសោធន៍ការងារជាក់ស្តែងក្នុងមុខជំនាញដែលមានវិញ្ញាបនប័ត្រអាជីវកម្មសាងសង់ ឬសិក្សាគម្រោងប្លង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសមាជិកគណៈវិស្វករកម្ពុជាដែលមានការទទួលស្គាល់ និងមានការយល់ព្រមពីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អាចដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណប្រកបសេវាកម្មជាក្រុមហ៊ុនវិស្វកម្មឯករាជ្យទៅតាមទម្រង់ដែលបានរៀបចំដោយក្រុមការងារអន្តរក្រសួង នៅលេខាធិការដ្ឋាននៃក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុដែលមានទីតាំងនៅការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ៣: - ថ្លៃអាជ្ញាប័ណ្ណ**

អ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណប្រកបសេវាកម្មជាក្រុមហ៊ុនវិស្វកម្មឯករាជ្យ ត្រូវបង់ថ្លៃអាជ្ញាប័ណ្ណចំនួន ២.០០០.០០០៛ (ពីរលានរៀល)។

ថ្លៃអាជ្ញាប័ណ្ណត្រូវបង់ទៅអគ្គនាយកដ្ឋានរតនាគារជាតិ តាមដីកាអមរបស់ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ។

**ប្រការ៤: - សុពលភាពអាជ្ញាប័ណ្ណ**

អាជ្ញាប័ណ្ណនេះមានសុពលភាពរយៈពេល ៣ ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាប័ណ្ណឱ្យបាន ៣០ ថ្ងៃ មុនពេលអាជ្ញាប័ណ្ណនោះអស់សុពលភាព និងត្រូវបង់ថ្លៃបន្តដូចការស្នើសុំលើកដំបូងដែរ ។

ក្រុមការងារអន្តរក្រសួងមានសិទ្ធិបន្តអាជ្ញាប័ណ្ណ ដោយមានដាក់ ឬមិនមានដាក់លក្ខខណ្ឌ ឬ មិនបន្តអាជ្ញាប័ណ្ណជូន ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវណាមួយដែលក្រុមការងារអន្តរក្រសួងបានកំណត់ ។

**ប្រការ៥: - ការព្យួរ ឬការដកហូតអាជ្ញាប័ណ្ណ**

ក្រុមការងារអន្តរក្រសួងមានសិទ្ធិព្យួរ ឬដកហូតអាជ្ញាប័ណ្ណ នៅពេលដែលអ្នកកាន់អាជ្ញាប័ណ្ណមិនបានគោរពទៅតាមលក្ខខណ្ឌណាមួយដូចមានចែងនៅក្នុងប្រកាសនេះ ឬមានចែងនៅក្នុងវិធាននៃការប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់វិស្វករឯករាជ្យ ។

ក្នុងករណីព្យួរ ឬដកហូតអាជ្ញាប័ណ្ណ ក្រុមការងារអន្តរក្រសួងនឹងចេញលិខិតជាលាយលក្ខណ៍អក្សរស្តីពីការព្យួរ ឬដកហូតអាជ្ញាប័ណ្ណ ទៅឱ្យអ្នកកាន់អាជ្ញាប័ណ្ណដោយបញ្ជាក់ពីមូលហេតុនៃការព្យួរ ឬ ការដកហូតអាជ្ញាប័ណ្ណនោះ ។

បន្ទាប់ពីការព្យួរ ឬដកហូតអាជ្ញាប័ណ្ណហើយ អ្នកកាន់អាជ្ញាប័ណ្ណត្រូវបញ្ឈប់ជាបន្ទាន់នូវការផ្តល់សេវាកម្មជាវិស្វករឯករាជ្យតទៅទៀត រហូតដល់មានការសម្រេចជាថ្មីពីក្រុមការងារអន្តរក្រសួង ទើបអាចបន្តសេវាកម្មរបស់ខ្លួនបាន ។

**ប្រការ៦: - កាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណ**

បន្ថែមពីលើការគោរពទៅតាមវិធាននៃការប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់វិស្វករ ឯករាជ្យ អ្នកកាន់អាជ្ញាប័ណ្ណត្រូវមានកាតព្វកិច្ចដូចតទៅ ÷

- ត្រូវអនុវត្តការងាររបស់ខ្លួនឱ្យបានហ្មត់ចត់ និងច្បាស់លាស់មុននឹងចេញលិខិតធានា ឬឯកសារបញ្ជាក់អំពីភាពរីកចំរើននៃគំរោងអភិវឌ្ឍអចលនវត្ថុ របស់បុគ្គលអភិវឌ្ឍអចលនវត្ថុដែលខ្លួនទទួលខុសត្រូវ ដើម្បីស្នើសុំដកប្រាក់ពីគណនីអភិវឌ្ឍអចលនវត្ថុទៅតាមសមាមាត្រដែលបុគ្គលអភិវឌ្ឍអចលនវត្ថុធ្វើបាន
- ត្រូវរក្សាឯកសារវាយតម្លៃសម្រាប់ធ្វើជាភស្តុតាងក្នុងការស៊ើបអង្កេត និងសម្រាប់តម្រូវការផ្សេងៗទៀតតាមស្ថានភាពជាក់ស្តែង
- ត្រូវទទួលខុសត្រូវទាំងស្រុងទៅលើកិច្ចការ និងរបាយការណ៍ដែលខ្លួនបានធ្វើ
- ត្រូវផ្តល់សេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់
- ត្រូវប្រកាន់ឯករាជ្យភាព និងមិនលំអៀងក្នុងការអនុវត្តកាតព្វកិច្ចវិជ្ជាជីវៈ
- មិនត្រូវទទួលធ្វើការងារណាដែលមិនស្ថិតនៅក្នុងសមត្ថភាពវិជ្ជាជីវៈ ឬដែលខ្លួនមិនយល់ដឹងនោះឡើយ
- មិនត្រូវធ្វើការបញ្ជាក់ទៅលើការងារណាដែលខ្លួនមិនបានធ្វើ ឬដែលខ្លួនមិនបានត្រួតពិនិត្យនោះឡើយ

- មិនត្រូវទទួលការងារពីអតិថិជនឡើយក្នុងករណីដែលខ្លួនមិនអាចបំពេញការងារតាមពេលកំណត់បាន

- ត្រូវធ្វើវិញ្ញត្តិដល់ក្រុមការងារអន្តរក្រសួង (ដោយមូលហេតុសមរម្យ /កំណត់ពេលវេលា ច្បាស់លាស់) នូវការប្រែប្រួល ឬការយឺតយ៉ាវលើសេវារបស់ខ្លួន

- ត្រូវផ្តល់នូវឯកសារដែលខ្លួនបានត្រួតពិនិត្យពេញលេញ មកក្រុមការងារអន្តរក្រសួងឱ្យបានទៀងទាត់ និងទាន់ពេលវេលា ហើយឯកសារនោះត្រូវតែបញ្ជាក់ថា ការងារដែលខ្លួនបានចុះត្រួតពិនិត្យពិតជាត្រឹមត្រូវ និង ច្បាស់លាស់តាមលទ្ធផលការងារដែលបុគ្គលអភិវឌ្ឍអចលនវត្ថុបានអនុវត្តមែន

- ត្រូវរាយការណ៍មកក្រុមការងារអន្តរក្រសួងឱ្យបានទាន់ពេលវេលាពីការលំបាក និងភាពមិនប្រក្រតី ដែលបង្កឡើងដោយបុគ្គលអភិវឌ្ឍអចលនវត្ថុដែលខ្លួនបំរើការងារជូន

- មិនត្រូវផ្តល់សេវាជូនបុគ្គលអភិវឌ្ឍអចលនវត្ថុណាដែលពុំទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឡើយ

- មិនត្រូវពន្យាការសំរេច ឬការបញ្ជាក់លើលិខិតស្នើសុំដកប្រាក់របស់អតិថិជនដោយពុំបានបញ្ជាក់ មូលហេតុឱ្យបានច្បាស់លាស់ឡើយ

- មិនត្រូវមានចេតនាពន្យារ ឬអូសបន្លាយការងារត្រួតពិនិត្យឡើយ ។

**ប្រការ៧: - ការត្រួតពិនិត្យ**

ក្នុងករណីមានការសង្ស័យ ប្រធានក្រុមការងារអន្តរក្រសួងអាចចាត់មន្ត្រីជំនាញរបស់ខ្លួនដើម្បីចុះត្រួតពិនិត្យដល់ទីកន្លែងលើឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងការងារវាយតម្លៃរបស់អ្នកកាន់អាជ្ញាប័ណ្ណ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីជំនាញរបស់ក្រុមការងារអន្តរក្រសួងក្នុងការពិនិត្យបញ្ជីស្មាម និងឯកសារផ្សេងៗ ។

**ប្រការ៨: - ការដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តខុសឆ្គង**

ក្រុមការងារអន្តរក្រសួង មានសិទ្ធិដកហូតការងារ ឬអាជ្ញាប័ណ្ណប្រកបសេវាកម្មជាវិស្វករឯករាជ្យ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមិនគោរពប្រតិបត្តិតាមការណែនាំដូចមានចែងក្នុងប្រកាសនេះ ឬមានចែងក្នុងវិធាននៃការប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈនោះទេ ។ បន្ថែមលើនោះក្រុមការងារអន្តរក្រសួងត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាអាណាព្យាបាលគ្រប់គ្រងលើវិជ្ជាជីវៈរបស់អ្នកកាន់អាជ្ញាប័ណ្ណឱ្យបានជ្រាបអំពីបទល្មើសដែលអ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្ត ដើម្បីចាត់វិធានការទៅតាមផ្លូវច្បាប់ជាធរមាន ។

**ប្រការ៩: - របាយការណ៍បញ្ចប់គម្រោង**

ក្រុមហ៊ុនវិស្វកម្មឯករាជ្យត្រូវផ្តល់របាយការណ៍វាយតំលៃបញ្ចប់គម្រោងសាងសង់ របស់បុគ្គលអភិវឌ្ឍអចលនវត្ថុ មកក្រុមការងារអន្តរក្រសួងឱ្យបានមុនពេលដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចេញលិខិតបិទការដ្ឋានសាងសង់។

**ប្រការ១០:** - **ការអនុវត្តប្រកាស**

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ គ្រប់នាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធដទៃទៀតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណវិស្វកម្មឯករាជ្យ បុគ្គលអភិវឌ្ឍអចលនវត្ថុទាំងអស់ដែលពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន

« ដើម្បីជូនជ្រាប »

**កន្លែងទទួល:**

- ដូចមានក្នុងប្រការ ១០

« ដើម្បីអនុវត្ត »

- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ